ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ ០០៣ ស.ក.ប.យ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០០៤

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សង្កេតឃើញថា កន្លងមករោងចក្រសហគ្រាសជាទូទៅ បានខិតខំអនុវត្តល្អពីលក្ខខណ្ឌការងារ ក៏ដូចជាវិធានអនាម័យនិងសន្តិសុខការងារ ។ រយៈពេលកន្លងមកថ្មីៗនេះ មានបាតុភូតកម្មករវិលមុខ ដួលសន្លប់ ដែលជាហេតុបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់និងការងារនៅរោងចក្រមួយចំនួន ។ ដើម្បីជៀសវាងនូវបាតុភូតមិនល្អទាំងនេះ និងដើម្បីរក្សាសុខភាព សុវត្ថិភាព របស់កម្មករនិយោជិតផង ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា សូមធ្វើការណែនាំដល់ម្ចាស់ និងនាយករោងចក្រ សហគ្រាស ពិសេសរោងចក្រកាត់ដេរសំលៀកបំពាក់និងដេរស្បែកជើង ដូចខាងក្រោមនេះ :

១-ត្រូវអនុវត្តឱ្យបានត្រឹមត្រូវនូវប្រកាស :

-លេខ១២៥ ស.ក.ប.យ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការបញ្ចេញបញ្ចូលខ្យល់និងការសំអាតបរិយាកាស ជាអាទិ៍ "ការបញ្ចេញបញ្ចូលខ្យល់ក្នុងទីកន្លែងធ្វើការដែលគ្មានបរិយាកាសក្រខ្វក់ ត្រូវធ្វើដោយការបក់បញ្ចូលខ្យល់តាមធម្មជាតិ ឬដោយសិប្បនិម្មិត " " ផ្ទៃក្រឡានៃទ្វារ បង្អួច រន្ធខ្យល់ទាំងអស់សរុបគ្នាមិនត្រូវឱ្យទាបជាង មួយភាគបួននៃផ្ទៃក្រឡារោងជាងឡើយ"

-លេខ១៤៧ ស.ក.ប.យ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីបរិយាការណ៍កំដៅក្នុងទីកន្លែងធ្វើការ ជាអាទិ៍ " ក្នុងករណីដែលទីកន្លែងធ្វើការមានកំដៅឡើងខ្លាំង ធ្វើឱ្យប៉ះពាល់ដល់សុខភាព ឬធ្វើឱ្យទើសទាល់ដល់ការងាររបស់កម្មករនិយោជិត និយោជកត្រូវរកគ្រប់មធ្យោបាយដើម្បីធ្វើឱ្យទីកន្លែងធ្វើការបានត្រជាក់វិញ ដូចជាដាក់កង្ហារម៉ាស៊ីនស្រូបខ្យល់ ឬម៉ាស៊ីនត្រជាក់ជាដើម"

-លេខ ០៥៤ ស.ក.ប.យ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០០០ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ ជាអាទិ៍ " និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវផ្តល់ភេសជ្ជៈអនាម័យឱ្យបានគ្រប់គ្រាន់ដល់កម្មករនិយោជិតរបស់ខ្លួន" ។

២-ត្រូវប្រុងប្រយ័ត្នក្នុងការប្រើប្រាស់សារធាតុគីមីទាំងឡាយ ដូចជា Solvant Trichloréthylène, Perchloréthylène, ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។

៣-មិនត្រូវរៀបចំឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោង លើសពីការអនុញ្ញាតរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។/.

៤-នៅគ្រប់ពេលមានធ្វើការបន្ថែមម៉ោង ក្រៅពីប្រាក់ឈ្នួលបន្ថែមម៉ោង រោងចក្រ សហគ្រាសត្រូវមានការបំប៉នកម្មករនិយោជិតបន្ថែមទៀត ជាចំណីអាហារដែលមានជាតិស្ករ ដូចជាភេសជ្ជៈដែលមានជាតិស្ករ ឬនំផ្អែម ។ល។

៥-ក្នុងករណីមានបាតុភូតកម្មករវិលមុខ ដួលសន្លប់កើតឡើង រោងចក្រ សហគ្រាសត្រូវជូនដំណឹងភ្លាម ទៅអគ្គនាយកដ្ឋានការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (អគារលេខ២៨ ផ្លូវលេខ១៨៤ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ទូរស័ព្ទ ០២៣ ៧២៤ ២៩១-០២៣ ៧២៥ ០៩២-០២៣ ៧២២ ៨៩១) ដើម្បីក្រសួងចាត់គណៈកម្មការអង្កេតចុះស្រាវជ្រាវរកមូលហេតុជាក់ស្តែង និងចាត់វិធានការកុំឱ្យមានបាតុភូតនេះកើតមានជាថ្មី ។

រោងចក្រ សហគ្រាសត្រូវតែផ្តល់ឱកាសនិងលទ្ធភាពដល់គណៈកម្មការអង្កេតរបស់ក្រសួង បានបំពេញមុខងាររបស់ខ្លួន អនុលោមតាមប្រកាសលេខ ២៤៣ ស.ក.ប.យ ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០០២ ស្តីពីការជូនដំណឹងគ្រោះថ្នាក់ការងារ របៀបផ្តល់តាវកាលិក និងអត្រាបាត់បង់សមត្ថភាពការងារ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងចាត់វិធានការតឹងរឹងបំផុត ទៅតាមច្បាប់ ចំពោះម្ចាស់ ឬនាយករោងចក្រ សហគ្រាសណាដែលប្រព្រឹត្តល្មើសលើចំណុចដែលបានរៀបរាប់ខាងលើ នៃសេចក្តីជូនដំណឹងនេះ ព្រមទាំងប្រកាសនានារបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាកន្លងមក ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ និងនាយករោងចក្រ សហគ្រាសទាំងអស់ និងអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរជាពុំខាន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**អ៊ិត សំហេង**

**ចម្លងជូន :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- -អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនៃក្រសួង ស.ក.ប.យ
- -អគ្គនាយកដ្ឋានការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -គ្រប់មន្ទីរ ស.ក.ប.យ ខេត្ត ក្រុង "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- -សមាគមនិយោជក "ដើម្បីអនុវត្ត"
- -សហព័ន្ធសហជីព "ដើម្បីជូនជ្រាប"
- -គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- -កាលប្បវត្តិនិងឯកសារ